# សុន្ទរកថាសំខាន់

## ថ្លែងដោយ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ក្នុងពិធីប្រគល់ជ័យលាភី

## អាហារូបករណ៍ជាតិ សម្តេចតេជោ ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨

## រៀបចំដោយ : សាកលវិទ្យាល័យកម្ពុជា

## វិទ្យាស្ថាន ជាតិអប់រំ

## រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០០៨

- **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ**
- **លោកបណ្ឌិត ហារុហ៊ីសា ហាន់ដា ប្រធាន មូលនិធិអន្តរជាតិដើម្បីសិល្បៈ និង វប្បធម៌ នៃប្រទេសជប៉ុន និងជាអធិការបតី នៃសាកលវិទ្យាល័យកម្ពុជា**
- **ក្មួយៗ ជានិស្សិតអាហារូបករណ៍ ទាំងអស់ជាទីមេត្រី !**

ថ្ងៃនេះ ខ្ញុំមានមនោសញ្ចេតនារីករាយជាអនេក ដោយបានមកចូលរួមជាមួយ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាមាតាបិតា និង ជាអាណាព្យាបាលសិស្សានុសិស្សទាំងអស់ ក្នុងពិធីប្រគល់ " **ជ័យលាភី អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** " ជូនក្មួយៗ ដែលទើបនឹងប្រឡងជាប់ សញ្ញាបត្រ ថ្នាក់មធ្យមសិក្សាទុតិយភូមិ នៅទូទាំងប្រទេស ។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមថ្លែងអំណរគុណចំពោះ **លោកបណ្ឌិត ហារុហ៊ីសា ហាន់ដា** (Haruhisa Handa) អ្នកដឹកនាំអង្គការ World Mate ស្ថាបនិក និងជាប្រធាន មូលនិធិអន្តរជាតិដើម្បីសិល្បៈ និង វប្បធម៌ នៃទីក្រុងតូក្យូ - ប្រទេសជប៉ុន និងជាអធិការបតី នៃសាកលវិទ្យាល័យកម្ពុជា ដែលជានិច្ចកាលតែងជួយឧបត្ថម្ភគាំទ្រ ដល់វិស័យអប់រំថ្នាក់ឧត្តមសិក្សា នៅប្រទេសកម្ពុជា ជាពិសេសគឺ ការឧបត្ថម្ភអាហារូបករណ៍ពេញថ្លៃ (១00%) **៥00 កន្លែងទៀត** (ក្នុងឆ្នាំ ២០០៨ នេះ បន្ថែមទៅលើអាហារូបករណ៍ **ចំនួន ៥00 កន្លែង** ដែលបានឧបត្ថម្ភកាលពីឆ្នាំ ២០០៧ ) ជូនដល់សិក្សានុសិស្សថ្នាក់ទី ១២ ទូទាំងប្រទេស ដែលបានប្រឡងជាប់ សញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ និង ទទួលបាននិទ្ទេសល្អ ក្នុងឆ្នាំសិក្សា ២០០៧ – ២០០៨ នេះ ។

ឆ្លៀតឱកាសនេះដែរ ខ្ញុំសូមសរសើរ សាកលវិទ្យាល័យកម្ពុជា ដែលតែងយកចិត្តទុកដាក់ ខិតខំស្វែងរកអាហារូបករណ៍ ជូននិស្សិតពូកែ តែមានជីវភាពក្រីក្រ ឱ្យបានបន្តការសិក្សាទៅថ្នាក់ឧត្តម និង ខិតខំលើកស្ទួយគុណភាពអប់រំ ថ្នាក់ឧត្តមសិក្សា និងការអភិវឌ្ឍធនធានមនុស្ស ដើម្បីរួមចំណែក កសាង និង អភិវឌ្ឍប្រទេសជាតិយើង ឱ្យបានរុងរឿងទៅអនាគត ។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**
- **ក្មួយៗ សិស្សានុសិស្សទាំងអស់ ជាទីមេត្រី !**

មុខព្រួញជាអាទិភាពដ៏សំខាន់ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល ក្នុងអាណត្តិថ្មីនោះគឺ ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ។ ជានិច្ចកាល ដើម្បីសំរេចគោលដៅនេះ រាជរដ្ឋាភិបាលតែងតែយកចិត្តទុកដាក់ជាសំខាន់ លើកំណើនសេដ្ឋកិច្ច ការបង្កើតការងារជូនប្រជាជន ការលើកស្ទួយសមធម៌ក្នុងសង្គម និងការពង្រឹងប្រសិទ្ធភាពក្នុងកិច្ចការសាធារណៈ ។ ការបណ្តុះធនធានមនុស្សក្នុងដំណាក់កាលនេះ គឺជាចម្លើយដ៏ត្រឹមត្រូវមួយ ទៅលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដែលជាកត្តាដ៏សំខាន់បំផុតដល់ការ កាត់បន្ថយភាពក្រីក្រ និងការលើកស្ទួយគុណភាព នៃជីវភាពរស់នៅរបស់ប្រជាជនយើង ។

ជាការពិតណាស់ បច្ចុប្បន្ននេះ សន្ទុះរីកសាយឡើង នៃចំនួនគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និង ឯកជន នៅតាមបណ្តាខេត្ត - ក្រុងនានា ទូទាំងប្រទេស បានផ្តល់នូវមោទនភាពដល់ប្រទេសជាតិយើង ។ ក៏ប៉ុន្តែ តុល្យភាពខាងបរិមាណ និង គុណភាពពុំទាន់ត្រូវបានត្រួតពិនិត្យឱ្យបាន ល្អិតល្អន់នៅឡើយ ។ ដូច្នេះ ខ្ញុំសូមឆ្លៀតឱកាសនេះ ស្នើសុំឱ្យគ្រឹះស្ថានឧត្តមសិក្សា ទាំងគ្រឹះស្ថានរដ្ឋ និង ឯកជនខិតខំពង្រឹងគុណភាពអប់រំ ពង្រីក សម្បទាសិក្សា និង កម្មវិធីហ្វឹកហ្វឺនអោយបានល្អ ប្រកបដោយវិទ្យាសាស្ត្រ និង បច្ចេកវិទ្យាដើម្បីធានាអោយស្តង់ដារអប់រំសិក្សាថ្នាក់ឧត្តម របស់យើង មានគុណភាពស្មើស្តង់ដារក្នុងតំបន់ និង អន្តរជាតិ ។ សូមខិតខំប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាយើង អោយទៅជាមជ្ឈមណ្ឌល នៃការប្រកួតប្រជែងផលិតផលធនធានបញ្ញវ័ន្តដ៏ទំនើប និង មានប្រសិទ្ធភាពមួយ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារពលកម្ម នៅក្នុងតំបន់ និង នៅលើពិភពលោក ។

សារៈសំខាន់ នៃការអប់រំ និង ការបណ្តុះបណ្តាល ធនធានមនុស្ស សំរាប់ប្រទេសជាតិមួយ ពុំមែនគ្រាន់តែដើម្បីលើកស្ទួយវឌ្ឍនភាពលើវិស័យ សេដ្ឋកិច្ចទេ តែគឺដើម្បីលើកស្ទួយកិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រទេសជាតិ តាមរយៈការប្រើប្រាស់ចំណេះដឹង សីលធម៌រស់នៅថ្លៃថ្នូ គតិបណ្ឌិត ផ្លូវចិត្ត និង សុច្ចរិតធម៌ ដែលទាំងអស់នេះគឺជា វប្បធម៌ដែលនាំឱ្យសង្គមជាតិមានការរីកចំរើន ប្រកបដោយភាពសុខដុម និង សន្តិភាព ។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**
- **ក្មួយៗ សិស្សានុសិស្សទាំងអស់ ជាទីស្រឡាញ់ !**

ភាពជឿនលឿន និង រុងរឿង នៃប្រទេសជាតិមួយ គឺអាស្រ័យដោយ បញ្ញវ័ន្តដែលមានតួនាទីគន្លឹះ ក្នុងការផ្តល់ចំណេះដឹងការអបរំ និង ការអភិវឌ្ឍ ។ ប្រាកដណាស់ បើស្រទាប់បញ្ញវ័ន្តកាន់តែសម្បូរ ការវិវត្តរីកចំរើនរបស់សង្គម ក៏កាន់តែឆាប់រហ័ស ។ ក្នុងសម័យកាលនៃ ពត៌មានវិទ្យា នាសតវត្សទី ២១នេះ តួនាទីរបស់បញ្ញវ័ន្តពិតជាថ្លៃថ្លា និងជាកត្តាកំណត់ក្នុងការជម្រុញ សក្តានុពលសេដ្ឋកិច្ច និងការអភិវឌ្ឍ របស់ប្រទេសជាតិ ប្រកបដោយចំណេះដឹង និង ទេពកោសល្យ ។ ដូច្នេះការអភិវឌ្ឍធនធានមនុស្សគឺជាកត្តាសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច និង កាត់បន្ថយភាពក្រីក្រ ។ គឺតម្លៃនៃការអប់រំនេះហើយ ដែលប្រែក្លាយបុគ្គលិកលក្ខណៈរបស់មនុស្សអោយទៅជា ជនអភិវឌ្ឍ ប្រកបដោយចំណេះដឹង នឹងមនសិការវិជ្ជាជីវៈ ដែលប្រទេសជាតិ និង ប្រជាជនយើងកំពុងត្រូវការ ។

ទាំងអស់នេះ គឺជាសារៈនៃការអប់រំ ដើម្បីប្រែក្លាយធនធាននិស្សិតយើងឱ្យទៅជា « និស្សិតល្អ ជាបញ្ញវ័ន្តបន្តវេន និងជាពលរដ្ឋល្អ » ទៅអនាគត ស្របតាមគោលការណ៍ជាមូលដ្ឋាន នៃការអប់រំ ដែលសំដៅការបង្កើនចំណេះដឹង ចំណេះធ្វើ មនសិការវិជ្ជាជីវៈ និងការរួមរស់ ក្នុងសង្គមប្រកបដោយភាពសុខដុម ។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**
- **ក្មួយៗ ជានិស្សិតអាហារូបករណ៍ថ្មី.......!**

តទៅនេះ ដើម្បីបានជាមតិយោបល់ខ្លះ សំរាប់ជួយឱ្យការសិក្សារបស់ក្មួយៗ បានជោគជ័យនៅថ្នាក់ សកលវិទ្យាល័យ ខ្ញុំសូមជូនយោបល់ខ្លះ ដូចខាងក្រោម :

**១. សម័យកាលនេះ គឺជាសម័យកាលនៃចំណេះដឹង :**

សម័យកាលនេះ គឺជាសម័យកាលប្រកួតប្រជែង សម័យកាលសិក្សា ស្រាវជ្រាវ សម័យកាលបច្ចេកវិជ្ជាពតិមាន សម័យកាលសេដ្ឋកិច្ច និង ចំណេះដឹង និងជាសម័យកាលសាកលភាវូបនីយកម្ម ។ ប្រសិនបើក្មួយៗក្នុងសម័យនេះ ពុំមានការយល់ដឹងជ្រាលជ្រៅ ឬ ពុំមានការរៀនសូត្រ អោយបានខ្ពស់ទេ នោះក្មួយៗ ពុំអាចរស់នៅបានល្អ ក្នុងសម័យកាលនេះឡើយ ។ ដូច្នេះ ការសិក្សាបន្តទៅថ្នាក់ឧត្តម ដើម្បីឱ្យបានទទួល ចំណេះដឹងជ្រៅជ្រះ ទាំងវប្បធម៌ទូទៅ ទាំងចំណេះដឹងខាងវិទ្យាសាស្ត្របច្ចេកទេស សីលវិជ្ជា បច្ចេកវិជ្ជាពតិមាន និង ភាសាអន្តរជាតិ គឺជាការចាំបាច់ណាស់ ។ សូមក្មួយៗ ខិតខំក្រេបជញ្ជក់យកចំណេះដឹងទាំងនេះអោយបានច្រើន នោះទើបអាចរស់នៅបានល្អប្រសើរ ក្នុង សម័យកាលនេះ ។

**២. ការសិក្សានៅថ្នាក់សាកលវិទ្យាល័យ ពុំដូចគ្នានឹង ការសិក្សានៅថ្នាក់មធ្យមទេ :**

ជាការពិតណាស់ ការសិក្សានៅថ្នាក់មធ្យម វាទាមទារអោយមានការទន្ទេញច្រើន និង ការសូត្រច្រើន ដើម្បីអោយក្មួយៗមានការ ចងចាំ ។ នៅថ្នាក់មធ្យមសិក្សា គ្រូតែងតែតាមបង្រៀនយើង ទោះបីយើងចង់រៀនក្តី – មិនចង់រៀនក្តី គ្រូតែងតែតាមបញ្ចុក ចំណេះដឹងអោយយើងជានិច្ច ។ ក៏ប៉ុន្តែ ការសិក្សានៅថ្នាក់សាកលវិទ្យាល័យពុំដូច្នោះទេ ។ នៅថ្នាក់សាកលវិទ្យាល័យ គ្រូឈប់តាមបញ្ចុកចំណេះវិជ្ជា ឱ្យយើងទៀតហើយ ។ សិស្សថ្នាក់សាកលវិទ្យាល័យ ត្រូវខិតខំស្វះស្វែងរៀនសូត្រដោយខ្លួនឯង ។ គ្រូគ្រាន់តែចាំជួយណែនាំ និង កែលំអការសិក្សារបស់យើងតែប៉ុណ្ណោះ ។ នៅថ្នាក់សាកលវិទ្យាល័យ គ្រូតែងបង្រៀនអោយយើងចេះគិត ចេះវិភាគ ចេះតស៊ូមតិ ចេះស្រាវជ្រាវ ចេះនិពន្ធ ចេះនិយាយ ចេះសម្តែងមតិ ចេះគិតគូរគ្រប់បញ្ហា ក្នុងជីវិត និង សង្គម ពោលគឺ អោយយើងចេះឈរលើ ជើងពីររបស់យើង ។

**៣. អំពីគុណសម្បត្តិ ដែលត្រូវមានសម្រាប់ការសិក្សានៅថ្នាក់សាកលវិទ្យាល័យ :**

ការសិក្សានៅសាកលវិទ្យាល័យ តម្រូវអោយមាន ៖

- ការគ្រប់គ្រងពេលវេលាអោយបានល្អបំផុត បើពុំដូច្នោះទេ ការសិក្សានោះ ពុំមានគុណភាពឡើយ ។ និស្សិតគ្រប់រូបត្រូវចេះ បែងចែកពេលវេលាសិក្សារបស់ខ្លួនឱ្យបានល្អ ទៅតាមកម្មវិធីសិក្សាប្រចាំថ្ងៃ - ប្រចាំសប្តាហ៍ - ប្រចាំឆមាស និង ប្រចាំឆ្នាំ ។

- តម្រូវអោយមានការប្រមូលអារម្មណ៍ ខិតខំសិក្សាឱ្យបានល្អ ចៀសវាង ភាពរវើរវាយ អណ្តែតអណ្តូង ឬ ភាពរាយមាយក្នុងការសិក្សា ។ រាល់ភាពខ្ជិលខ្ជារ និងការមិនយកចិត្តទុកដាក់ គឺជាភាពបរាជ័យ ក្នុងការសិក្សាថ្នាក់ឧត្តម ។
- តម្រូវឱ្យមានការរៀបចំផែនការ ឬ សកម្មភាពសិក្សាឱ្យបានត្រឹមត្រូវ និង ត្រូវមានវត្តមានឱ្យបានទៀងទាត់ នៅរៀងរាល់ ម៉ោងសិក្សានិមួយៗ ។
- តម្រូវឱ្យនិស្សិតចេះមានចម្ងល់ និង មានសេចក្តីក្លាហានក្នុងការបញ្ចេញមតិ : ហ៊ានសួរ – ហ៊ានដេញដោល – ហ៊ានវិភាគបញ្ហា ជាមួយមិត្តភ័ក្តិ និងជាមួយគ្រូ ដោយសេចក្តីក្លាហាន ។
- តម្រូវឱ្យមានការអានសៀវភៅ និងការសិក្សាស្រាវជ្រាវជាប់ជាប្រចាំ ។ គឺការអានសៀវភៅនេះហើយ ដែលជាប្រភពនៃចំណេះដឹង ដែលនិស្សិតត្រូវខិតខំយកចិត្តទុកដាក់ បន្ថែមទៅលើចំណេះដឹង ដែលគ្រូបានបង្ហាត់បង្ហាញ ។
- តម្រូវអោយមានការវាយតម្លៃទៅលើលទ្ធផល នៃការឆ្លុះបញ្ចាំងអំពី គុណភាពនៃការសិក្សារបស់ខ្លួន ។ និស្សិតថ្នាក់ឧត្តម ដែលជាអនាគតធនធានបញ្ញវ័ន្តបន្តវេន ចាំបាច់ត្រូវធ្វើការវាយតម្លៃទៅគុណភាព នៃការសិក្សារបស់ខ្លួន ។ ការឆ្លុះបញ្ចាំង អំពីគុណភាពនេះ ជាទូទៅត្រូវបានធ្វើឡើងតាមរយៈ ការវាយតម្លៃរបស់គណៈសាស្ត្រាចារ្យ – ការប្រឡងនៅគ្រប់ថ្នាក់ និងការ វាយតម្លៃរបស់សាលា ។ ក៏ប៉ុន្តែ ទោះជាដូចម្តេចក្តី ការវាយតម្លៃដោយខ្លួនឯង ការស្គាល់ខ្លួនឯង និង ស្គាល់ការយល់ដឹង របស់ខ្លួន ដោយខ្លួនឯង គឺជាការសំខាន់ណាស់ ដើម្បីកាត់បន្ថយការខ្វះខាត និងលើកស្ទួយគុណសម្បត្តិសិក្សា របស់ខ្លួន ។

## ៤_ បើពូកែលើមុខវិជ្ជាណា គួរយកមុខវិជ្ជានោះជា ឯកទេស :

ភាពមិនច្បាស់លាស់នីមួយរបស់និស្សិតថ្នាក់ឧត្តម នោះគឺការជ្រើសរើសមុខវិជ្ជាឯកទេស (Major) ។ បើជ្រើសរើសមុខវិជ្ជាឯកទេសខុសនោះ គុណភាព និង ប្រសិទ្ធភាពនៃការអប់រំសិក្សា នឹងមានកំរិតទាប ។ និស្សិតថ្នាក់ឧត្តម គួរតែប្រយ័ត្នប្រយែងក្នុងការ ជ្រើសរើសមុខវិជ្ជាឯកទេសរបស់ខ្លួន ។ តើនិស្សិតគួរជ្រើសរើស មុខវិជ្ជាឯកទេសរបស់ខ្លួនដូចម្តេច ? ចំពោះការជ្រើសរើសនេះ គេគួរតែជ្រើសរើសយកមុខវិជ្ជាឯកទេសណា ដែលគេស្រឡាញ់ពេញចិត្ត និងមាននិស្ស័យពីកំណើតរបស់ខ្លួន ។ ចូរកុំជ្រើសរើសយក មុខវិជ្ជាឯកទេសណា ដោយប្រថុយប្រថាន ឬដោយការស្រមើស្រមៃ ឬ ដោយយកតាមមតិអ្នកដទៃនោះ ពុំត្រឹមត្រូវទេ ។ និស្សិត គ្រប់រូបគួរតែធ្វើសេចក្តីសំរេចចិត្តដោយខ្លួនឯង ក្នុងការជ្រើសរើសមុខវិជ្ជាជំនាញ ដែលខ្លួនត្រូវយកធ្វើជាមុខរបរ សម្រាប់អនាគតរបស់ខ្លួន ។ ក្តួយពុំគួរស្តាប់អ្នកដទៃ ឬ សង្ឃឹមទៅលើអ្នកដទៃ ក្នុងការសម្រេចពីអនាគតរបស់ខ្លួនឡើយ ។

## ៥_ ការទទួលខុសត្រូវក្នុងការសិក្សា គឺជារបស់ខ្លួនឯង :

ការទទួលខុសត្រូវលើការសិក្សា គឺពុំមែនស្ថិតនៅលើ គណៈសាស្ត្រាចារ្យ ឬ មាតាបិតា និងអាណាព្យាបាលយើងទេ តែគឺជា របស់ខ្លួនយើង ។ មាតាបិតា ឬ គ្រូអាចារ្យ ឬ អាណាព្យាបាល គ្រាន់តែជាកម្លាំងខាងក្រៅតែប៉ុណ្ណោះ ។

ដូច្នេះដើម្បីអោយក្លាយខ្លួនជា បញ្ញវ័ន្តពិតប្រាកដ ក្មួយៗត្រូវខិតខំសិក្សាដោយខ្លួនឯង – ត្រូវខិតខំអានសៀវភៅអោយបានច្រើន – ត្រូវខិតខំធ្វើកិច្ចការដែល គ្រូដាក់អោយធ្វើនៅផ្ទះ – ត្រូវខិតខំកត់ត្រា – ខិតខំពិចារណាយកចំណេះដឹងរបស់គ្រូមកធ្វើជាចំណេះដឹងរបស់ខ្លួន តាមរយៈការទំពារអៀង – នោះទើបអាចក្លាយខ្លួនជាអ្នកចេះដឹងពិតៗ – ដែលអាចយកចំណេះដឹងនោះ មកធ្វើជារបស់ខ្លួន ដើម្បីបំរើខ្លួន និង សង្គមជាតិខ្លួនបាន ។

**៦. ត្រូវជួបគ្រូ ប្រសិនបើក្មួយៗរៀនខ្សោយ :**

ការជួបជាមួយគណៈសាស្ត្រាចារ្យ ឬ ជាមួយលោកគ្រូផ្ទាល់ ដែលបង្ហាត់មុខវិជ្ជាដែលក្មួយៗរៀនខ្សោយ គឺជាការសំខាន់ណាស់ ។ ប្រសិនបើក្មួយៗរៀនខ្សោយ – រៀនមិនទាន់គេ ឬរៀនធ្លាក់ ក្មួយៗត្រូវស្វែងរកយុទ្ធសាស្ត្រថ្មី ដើម្បីដោះស្រាយបញ្ហានោះ ឱ្យទាន់ពេលវេលា ។ យុទ្ធសាស្ត្រនោះគឺ : ត្រូវទៅជួបគ្រូ – ត្រូវទៅជួបទីប្រឹក្សាសាលា ឬ ត្រូវទៅជួបលោកព្រឹទ្ធបុរស ដើម្បីស្នើសុំការ ណែនាំ របស់គាត់ ឱ្យក្មួយៗរៀនពូកែឡើងវិញ ។

**៧. បើមានកម្លាំងចិត្តប្តេជ្ញា និង ការស្មោះត្រង់ នោះការសិក្សានឹងបានជោគជ័យ :**

បញ្ហាសំខាន់ក្នុងការសិក្សានោះគឺ ការតាំងចិត្ត ឬការជម្រុញទឹកចិត្តអោយខំសិក្សា ។ បើគ្មានកម្លាំងចិត្តទេ ការប្តេជ្ញាក៏គ្មានដែរ ។ កម្លាំងចិត្តសិក្សា គឺបានមកពីក្នុងចិត្តរបស់យើង ។ ដូច្នេះ ក្មួយៗត្រូវមានទឹកចិត្តស្រឡាញ់ការសិក្សា និងការប្តេជ្ញាខ្ពស់ នោះទើបការ សិក្សាទទួលបានជោគជ័យ ។

ម្យ៉ាងទៀត សេចក្តីស្មោះត្រង់ចំពោះការសិក្សា គឺជាកត្តាជម្រុញឱ្យការសិក្សានោះបានជោគជ័យ នឹងមានគុណភាព ។ ដូច្នេះ ក្មួយៗដាច់ខាតមិនត្រូវចម្លងអ្នកដទៃឡើយ ។ ការរៀនសូត្រដោយចម្លងពីអ្នកដទៃ ឬ លួចចម្លងគេ វាធ្វើអោយយើង បានពិន្ទុមែន តែរូបយើងនៅល្ងង់រហូត ។ សិស្សដែលលួចចម្លងគេ គឺជាសិស្សដែលបន្ទាបបន្ថោកខ្លួនឯង ។ ដូច្នេះ ក្មួយៗត្រូវមានសេចក្តីស្មោះត្រង់ ក្នុងការសិក្សារបស់ខ្លួន នោះទើបការសិក្សានោះមានគុណភាព និង ទទួលបានជោគជ័យ ។

ខ្ញុំសូមផ្តាំផ្ញើចំពោះក្មួយៗ ដែលទើបនឹងទទួលបាន **អាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុសហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** តែប៉ុណ្ណោះ ។

ខ្ញុំសង្ឃឹមថា ក្មួយៗនឹងយកសេចក្តីណែនាំរបស់ខ្ញុំទៅពិចារណា នឹងប្រែក្លាយសំណូមពរទាំងនេះ អោយទៅជាកម្លាំងជម្រុញទឹកចិត្ត ដ៏ខ្លាំងក្លាមួយ សម្រាប់លើកស្ទួយ ការសិក្សាឱ្យសម្រេចជោគជ័យ តាមគោលដៅ និង វត្ថុបំណងដែលសាកលវិទ្យាល័យកម្ពុជា និង ម្ចាស់អំណោយរំពឹងទុក ។

នៅទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណជាថ្មី ចំពោះគណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាពិសេសគឺលោកបណ្ឌិត ហារុហ៊ីសា ហាន់ដា និង គណៈប្រតិភូដែលបានអញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ « **ជ័យលាភីអាហារូបករណ៍ជាតិ សម្តេច ហ៊ុន សែន និស្សិតពូកែ – ហារុហ៊ីសា ហាន់ដា ឆ្នាំ ២០០៨** » នាពេលព្រឹកនេះ ។

ខ្ញុំសូមជូនពរ គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ អស់លោក លោកស្រី សូមឱ្យបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុះ វណ្ណះ សុខះ ពលះ** កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំ សូមអោយក្មួយៗ ជាជ័យលាភីទាំងអស់ មានសុខភាពមាំមួន និង ជួបតែសំណាងល្អ ក្នុងការសិក្សាជានិច្ចនិរន្តន៍ !

**សូមអរគុណ !**